**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ០២១ បទ.សរណ

# សេចក្តីណែនាំ

## ស្តីពី

## ការពង្រឹងគុណភាពសេវាទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ មេត្តាជ្រាបថា ចាប់តាំងពីមានព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ មក ទំហំនៃការប្រើប្រាស់សេវាអ៊ីនធឺណិតកាន់តែកើនឡើងគួរឱ្យកត់សម្គាល់។ ក្នុងន័យនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមធ្វើការណែនាំដល់ប្រតិបត្តិករផ្តល់សេវាទូរសព្ទចល័តនិងប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត (ISP) ទាំងអស់ ត្រូវពង្រឹងគុណភាពសេវាទូរគមនាគមន៍របស់ខ្លួន ដើម្បីសម្រួលដល់ការប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ ជៀសវាងភាពរអាក់រអួលក្នុងទំនាក់ទំនងសង្គម ការសិក្សា និង ការបំពេញការងារពីចម្ងាយតាមប្រព័ន្ធអនឡាញ (Online) ជាដើម។

អាស្រ័យហេតុនេះ សូមប្រតិបត្តិករទូរគមនាគមន៍ទាំងអស់អនុវត្តតាមការណែនាំខាងលើ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ចន្ទ ៩កើត ខែចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០២១


អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.mptc.gov.kh
ទូរសព្ទ : (៨៥៥) ២៣ ៧២៤ ៨១០
ទូរសារ : (៨៥៥) ២៣ ៧២៤ ០៦៩
អ៊ីមែល : info@mptc.gov.kh